**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ១៧៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យបញ្ញាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា



Downloaded from http://www.khmerlaws.com

# ស ម្រេ ច

**មាត្រា ១.-**

ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យ បញ្ញាជាតិ **Panha Chiet University** សរសេរកាត់ជាភាសាខ្មែរ ស.ប.ជ និងសរសេរកាត់ជាភាសា អង់គ្លេស **P.C.U** ។

**មាត្រា ២.-**

ស.ប.ជ មានទីតាំងស្ថិតនៅអគារលេខ ២០-២៤ -១៣ ផ្លូវលេខ ២១០ សង្កាត់ ទឹកល្អក់៣ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣.-**

ស.ប.ជ ធ្វើការបណ្តុះបណ្តាលកម្រិត បរិញ្ញាបត្ររង និងបរិញ្ញាបត្រ លើមហាវិទ្យាល័យប្រាំ :

១- មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសា

២- មហាវិទ្យាល័យ គណិតវិទ្យា និងវិទ្យាសាស្ត្រ

៣- មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម

៤- មហាវិទ្យាល័យ ធុរកិច្ច និងសេដ្ឋកិច្ច

៥- មហាវិទ្យាល័យ អប់រំ ។

ស.ប.ជ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ផ្តើមដំណើរការបណ្តុះបណ្តាល ។ ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខាមហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិតឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មី ឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួង អប់រំ យុវជន និងកីឡា ។

**មាត្រា ៤.-**

ស.ប.ជ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃ ស.ប.ជ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥.-**

សាកលវិទ្យាធិការ ស.ប.ជ មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រង ស.ប.ជ និងធានាឱ្យមានសុវត្ថិភាពសណ្តាប់ធ្នាប់សង្គម
- គោរព និងអនុវត្តតាមបទដ្ឋាន ដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ មកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

Downloaded from http://www.khmerlaws.com

**មាត្រា ៦.-**

និស្សិត ស.ប.ជ ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយ ស.ប.ជ ហើយ ត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី ស.ប.ជ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាភិបាល រួមជាមួយសាកលវិទ្យាធិការ នៃ ស.ប.ជ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com